**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :.........០៧១/២១.........ក.ប/ស.ជ.ណ.រ.ប.ប

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារពេល នៃការលក់ និងទទួលពាក្យ ប្រឡងប្រជែងជ្រើសរើសក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលឆ្នាំ២០២១

**យោង៖** សេចក្តីជូនដំណឹងលេខ ០០៤/២១ ក.ប/ស.ជ.ណ.រ.ប.ប ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលឆ្នាំ២០២១។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណៈជន សិស្ស-និស្សិត មន្ត្រីរាជការ បុគ្គលិកក្រុមហ៊ុន ឬអង្គការ ទាំងអស់ឱ្យបានជ្រាបថា គណៈកម្មការរៀបចំការប្រឡងក្របខណ្ឌសម្រាប់ឆ្នាំ២០២១ សូមពន្យារពេលនៃការលក់ និងទទួលពាក្យប្រឡងក្របខណ្ឌឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១។ ម្យ៉ាងវិញទៀតសម្រាប់ថ្ងៃប្រឡង បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីប្រឡងត្រូវបំពេញលក្ខខណ្ឌមួយចំនួនបន្ថែមដូចខាងក្រោម៖

១. ត្រូវធានាឱ្យបានក្នុងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ទាំងពីរលើករួចរាល់

២. ថ្ងៃប្រឡងបេក្ខជនទាំងអស់ត្រូវភ្ជាប់មកជាមួយនូវកាត ឬលិខិតសម្គាល់បានចាក់វ៉ាក់សាំង

៣. ក្នុងករណីដែលបេក្ខជនមិនអាចទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩បាន ត្រូវមានលិខិតបញ្ជាក់ពីមន្ទីរសុខាភិបាលរាជធានី ខេត្ត

៤. ក្នុងករណីបេក្ខជនរូបណាដែលមិនមានកាត ឬលិខិតចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ឬលិខិតបញ្ជាក់របស់មន្ទីរសុខាភិបាលរាជធានី ខេត្ត មិនត្រូវបានអនុញ្ញាតឱ្យចូលប្រឡងឡើយ

៥. ចំពោះកាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡង ក្រសួងនឹងជូនដំណឹងនៅពេលក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សិស្ស-និស្សិត មន្ត្រីរាជការ បុគ្គលិកក្រុមហ៊ុន ឬអង្គការ ដែលមានបំណងចង់ដាក់ពាក្យសុំប្រឡងជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១១រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ក្រសួងព័ត៌មាន
- គ្រប់អង្គភាពចំណុះក្រសួង
- ឯកសារ-កាលប្បវត្តិ